# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ ១៨៦០..........បទ.........................

ថ្ងៃ សុក្រ ០២ កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩

**សូមគោរពជូន**

**ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**កម្មវត្ថុ:** របាយការណ៍ស្តីពីសកម្មភាពទូលំទូលាយនិងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំឆ្នាំ២០១៩និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០២០ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**ក - សកម្មភាពការងារប្រចាំ ឆ្នាំ២០១៩**

១-បានធ្វើការជម្រុញដល់អង្គភាពក្រោមឱវាទក្រសួងប.ទ.ដែលមានគេហទំព័រឲ្យផ្សព្វផ្សាយសារអប់រំជាប្រចាំ ទាំងបញ្ហាអេដស៍ បញ្ហាគ្រឿងញៀន និងចរាចរណ៍ជាដើម នៅលើគេហទំព័ររបស់ខ្លួន។

២-បានផ្សព្វផ្សាយសារអប់រំជាប្រចាំអំពីបញ្ហាអេដស៍ អំពីបញ្ហាគ្រឿងញៀន ក្នុងគេហទំព័រ និងក្នុងព្រឹត្តិប័ត្រប្រចាំត្រីរបស់ក្រសួងប.ទ.ដែលបាននិងកំពុងអនុវត្តរហូតបច្ចុប្បន្ន។

៣-បានបន្តការតាមដានលើសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈកម្មវិធីអប់រំអំពីបញ្ហាអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទតាមប្រព័ន្ធលេខទូរស័ព្ទខ្លី៤ខ្ទង់ ដែលបានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង និយ័តករទូរគមនាគមន៍កម្ពុជា៖

- ចំពោះអង្គការFHI360 ដែលប្រើលេខទូរស័ព្ទខ្លី "**១២៩៥**" សម្រាប់ការហៅចូលនិងឆ្លើយតបក្នុងកម្មវិធីអប់រំជាសម្លេងតាមទូរស័ព្ទ

- ដោយឡែកចំពោះការប្រើប្រាស់លេខ "**១២៩៣**"ដែលបានផ្តល់ឲ្យអង្គការ One World ពីពេលកន្លងទៅនោះ បច្ចុប្បន្ននេះពុំមានទៀតទេ ប៉ុន្តែរាល់ដំណើរការនៃសារអប់រំជាអក្សរឬជាសម្លេងតាមសំនួរ/ចម្លើយតាមទូរស័ព្ទដែត្រូវបានទទួលបន្ទុកដោយអង្គការជំនួយកុមារ Child Helpline ដោយប្តូរមកប្រើតាមលេខទូរស័ព្ទ **១២៨០** តែមួយ រួមគ្នាជាមួយការផ្តល់សេវាចំពោះកុមារមានបញ្ហាឬមានតម្រូវសុំអន្តរាគមជំនួយ ដែលធ្លាប់មានពីមុនស្រាប់នោះ ដោយបន្ថែមសេវាអប់រំអំពីបញ្ហាអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ រវាងសាធារណជន និងក្រុមប្រឹក្សាជំនាញ។ ឯលេខ **១២៩៣** ត្រូវបានប្រគល់ជូនមកនិយ័តករទូរគមនាគមន៍កម្ពុជាវិញ។

ចំពោះការប្រើប្រាស់លេខទូរស័ព្ទខ្លីទាំងពីរខាងលើនេះ ពុំមានគិតថ្លៃពីសាធារណជន នោះទេ។

**៤-សមាជិកក្រុមប្រឹក្សាបច្ចេកទេស** បានចូលរួមប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានអ.ជ.ប.ជ.អ.បាន **១០ លើក** នៅទីស្តីការអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ (អ.ជ.ប.ជ.អ.)។

**៥-គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

- បានប្រជុំពិភាក្សាធ្វើបច្ចុប្បន្នភាពស្តីពីការបង្កើតគណៈកម្មាធិការដែលត្រូវមានសមាសភាពសកម្ម

ព្រោះក្រសួងចាំបាច់ត្រូវបង្កើតគណៈកម្មាធិការមួយទទួលបន្ទុកការងារប្រយុទ្ធនឹងជំងឺអេដស៍រួមនឹងប្រយុទ្ធប្រឆាំងគ្រឿងញៀន បញ្ចូលគ្នាតែមួយដោយពុំចាំបាច់មានគណៈកម្មាធិការដល់ទៅពីរដោយឡែកពីគ្នា

- បានចូលរួមពិភាក្សាក្នុងការរៀបចំគម្រោងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ដែលមានការពាក់ព័ន្ធនឹងកញ្ចប់ថវិការបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ជាមួយក្រុមការងាររៀបចំថវិកាកម្មវិធីរបស់ក្រសួងប.ទ.នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានទៅចូលរួមកិច្ចប្រជុំពេញអង្គលើកទី០១ នាថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ នៅខេត្តកែប និងពេញអង្គលើកទី២ រួមនឹងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ លើកទិសដៅឆ្នាំ២០២០ របស់ អ.ជ.ប.ជ.អ.នាថ្ងៃទី០៥-០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅសាល គ ទីស្តីការគណៈរដ្ឋមន្ត្រីអគារមិត្តភាពដឹកនាំ ដោយ **ឯ.ឧ. អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអ.ជ.ប.ជ.អ.

- បានប្រជុំពិភាក្សាចំនួន០២លើក លើការងាររៀបចំប្រារព្ធកម្មវិធីសិក្ខាសាលា ស្តីពី " យុទ្ធសាស្ត្រចូលរួមបញ្ចប់ជំងឺអេដស៍ និងទប់ស្កាត់ការប្រើប្រាស់ ជួញដូរគ្រឿងញៀន "

- បានប្រារព្ធកម្មវិធីសិក្ខាសាលាស្តីពី" យុទ្ធសាស្ត្រចូលរួមបញ្ចប់ជំងឺអេដស៍និងទប់ស្កាត់ការប្រើប្រាស់ជួញដូរគ្រឿងញៀន " នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ ដោយមានថ្នាក់ដឹកនាំក្រសួង ប្រធាន ឬ តំណាងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍អន្តរក្រសួង/ស្ថាប័ននិងមន្ត្រីរាជការ និយោជិតក្រោមឱវាទក្រសួងប.ទ. តំណាង NCHADS អង្គការការដៃគូ ប្រតិបត្តិករបម្រើសេវាប្រៃសណីយ៍និងទូរគមនាគមន៍ ចូលរួមមានចំនួនសរុប ៤០០ នាក់ ស្ថិតក្រោមអធិបតីភាព **ឯកឧត្តម ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានចុះអប់រំផ្សព្វផ្សាយអំពីបញ្ហាទាក់ទងជំងឺអេដស៍/មេរោគអេដស៍និងបញ្ហាគ្រឿងញៀនជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនិងនិយោជិតក្រោមឱវាទមន្ទីរប.ទ.ខេត្តចំនួន០២(បន្ទាយមានជ័យនិងបាត់ដំបង)ដែលមានអ្នកចូលរួមសរុប៨០នាក់

-បានបន្តចូលរួមអន្តរាគមនិងសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជាស្នើទៅប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ ក្នុងការសរសេរសារSMSខ្លីៗដើម្បីផ្សព្វផ្សាយអប់រំទាក់ទងអំពីបញ្ហាអេដស៍បញ្ជូនទៅអ្នកកាន់ទូរស័ព្ទដៃ ជាពិសេសនាឱកាសបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នាថ្ងៃទី១០-១១-១២ ខែវិច្ឆិកា និងទិវាពិភពលោកប្រយុទ្ធ នឹង ជំងឺអេដស៍ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ កន្លងទៅ តាមខ្លឹមសារនៃសារទទួលបានពី អ.ជ.ប.ជ.អ.។

## ខ - ទិសដៅការងារសម្រាប់ ឆ្នាំ២០២០

១-បន្តរៀបចំសកម្មភាពចុះអប់រំផ្សព្វផ្សាយអំពីការទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងប្រយុទ្ធប្រឆាំងគ្រឿងញៀនជូនមន្ត្រីរាជការ និយោជិតនៅតាមមន្ទីរប.ទ.ខេត្តមួយចំនួន ដែលបានគ្រោងក្នុងកញ្ចប់ថវិការួចហើយ

២-បន្តរៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយអំពីការទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន ជូនមន្ត្រីរាជការ និយោជិត បុគ្គលិកប្រតិបត្តិករ ក្រោមឱវាទក្រសួងប.ទ.

៣-បន្តការសហការដោយផ្ទាល់ឬដោយប្រយោលជាមួយដៃគូអភិវឌ្ឍន៍នានានិងជាមួយអ.ជ.ប.ជ.អ.

៤-បន្តចូលរួមអន្តរាគមនិងសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជាស្នើទៅប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ ក្នុងការសរសេរសារSMSខ្លីៗដើម្បីផ្សព្វផ្សាយអប់រំទាក់ទងអំពីបញ្ហាអេដស៍ និងគ្រឿងញៀនបញ្ជូនទៅអ្នកកាន់ទូរស័ព្ទដៃ ជាពិសេសនាឱកាសបុណ្យជាតិដូចជា ចូលឆ្នាំថ្មី ភ្ជុំបិណ្ឌ អុំទូក បណ្តែតប្រទីប

សំពះព្រះខែ អកអំបុក និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ តាមខ្លឹមសារនៃសារទទួលបានពីអ.ជ.ប.ជ.អ. និងអ.ជ.ប.គ.៣.

៥-បន្តតាមដានត្រួតពិនិត្យ និងជួយផ្តល់ប្រឹក្សា ឬអន្តរាគមន៍ ដល់អង្គការដែលកំពុងប្រើប្រាស់លេខទូរស័ព្ទខ្លី ១២៩៥ និង១២៨០ ដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងការអប់រំអំពីជំងឺអេដស៍

៦-បន្តនិងជំរុញការផ្សព្វផ្សាយអប់រំអំពីបញ្ហាអេដស៍ បញ្ហាគ្រឿងញៀននៅលើគេហទំព័ររបស់ក្រសួង ប.ទ. អង្គភាពក្រោមឱវាទក្រសួង និងនៅក្នុងព្រឹត្តិប័ត្រប្រចាំត្រីមាសក្រសួងប.ទ.

៧-ចូលរួមប្រជុំតាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍(អ.ជ.ប.ជ.អ.)។

**គ - បញ្ហាប្រឈម:**

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប.ទ.ពុំទាន់មានលទ្ធភាពអាចស្រង់បាននូវទិន្នន័យអំពីប្រសិទ្ធភាពពាក់ព័ន្ធនឹងការយល់ដឹងឬការចែករំលែកចំណេះដឹងដែលជាកម្រិតបច្ចេកទេសអាចធ្វើបាន ក្រោយពីបានបញ្ជូនសារអប់រំតាមទូរស័ព្ទដៃទៅកាន់អ្នកប្រើប្រាស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**
**និងជាប្រធាន គ.ប.ជ.អ.ប.ទ.**

**ខាយ ឃុនហេង**

**ចម្លងជូន៖**
-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប.ទ.
" ដើម្បីគោរពជូនជ្រាប "
ឯកសារ-កាលប្បវត្តិ

website NAA
20-1-20